# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ណែនាំ
# ស្តីពី
# ការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់
# គិលានុបដ្ឋាក

# ២០១៧

Supported by:

implemented by

# តារាងអក្សរកាត់

| | |
|---|---|
| AJCCN | គណៈកម្មាធិការសម្របសម្រួលរួមអាស៊ានលើការថែទាំ |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CCN | គណៈគិលានុបដ្ឋាកកម្ពុជា |
| CPD | ការអភិវឌ្ឍជំនាញវិជ្ជាជីវៈជាបន្ត |
| GIZ | Deutsche Gesellschaft für Internationale Zusammenarbeit GmbH |
| HSP3 | ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០ នៃរាជរដ្ឋាភិបាលកម្ពុជា |
| IAI | គំនិតផ្តួចផ្តើមលើការធ្វើសមាហរណកម្មអាស៊ាន |
| ICN | ក្រុមប្រឹក្សាអន្តរជាតិនៃគិលានុបដ្ឋាក |
| MRA-NS | កិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើសេវាថែទាំ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| SDGs | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព របស់អង្គការសហប្រជាជាតិ |

# មាតិកា


តារាងអក្សរកាត់

អារម្ភកថា

សេចក្តីថ្លែងអំណរគុណ

សេចក្តីផ្តើម ............ ១

គណៈគិលានុបដ្ឋាកកម្ពុជា ............ ១

តួនាទីរបស់ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកកម្ពុជា ............ ២

ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ............ ២

ការអភិវឌ្ឍវិជ្ជាជីវៈបន្តក្នុងបរិបទទីកន្លែងប្រកបវិជ្ជាជីវៈ ............ ៣

ភាពចាំបាច់នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ............ ៣

អត្ថប្រយោជន៍ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ............ ៤

គោលការណ៍សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ............ ៥

គោលដៅការអភិវឌ្ឍវិជ្ជាជីវៈបន្ត ............ ៦

សកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត ............ ៦

លក្ខណៈវិនិច្ឆ័យ/តម្រូវការ និងការទទួលស្គាល់ ............ ៧

ជំហ៊ាននៃ CPD ............ ៩

ទិដ្ឋភាពទូទៅនៃប្រព័ន្ធ Credit ............ ១០

ទំនាក់ទំនងសំខាន់ៗ៖ ............ ១២

ឧបសម្ព័ន្ធទី១៖ ដំណើរការចុះបញ្ជីគិលានុបដ្ឋាក ............ ១៣

ឧបសម្ព័ន្ធទី២៖ កំណត់ត្រាសកម្មភាពបុគ្គល ............ ១៤

ឧបសម្ព័ន្ធទី៣៖ អង្គភាពក្នុងស្រុកដែលជាតំណាងឲ្យ CNN ............ ១៧

# អារម្ភកថា

ការកំណត់គោលការណ៍ណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់គិលានុបដ្ឋាកទូទាំងព្រះរាជាណាចក្រកម្ពុជា ទាំងស្ថាបនរដ្ឋ ឯកជន កងកម្លាំងប្រដាប់អាវុធ និងជនបរទេសមានសារៈសំខាន់បំផុតក្នុងការបង្កើនសមត្ថភាពទាំងចំណេះដឹង ជំនាញ និងឥរិយាបថដើម្បីផ្តល់សេវាថែទាំដែលមានគុណភាព និងសុវត្ថិភាពដល់អតិថិជន។

គណៈគិលានុបដ្ឋាកកម្ពុជាបានសហការជាមួយអង្គការ GIZ និងក្រុមការងារបច្ចេកទេសមកពីមន្ទីរពេទ្យជាតិ និងមន្ទីរពេទ្យកុមារអង្គរបានរៀបចំគោលការណ៍ណែនាំនេះ ដែលជាមូលដ្ឋានគ្រឹះសម្រាប់បំពេញលក្ខខណ្ឌកំណត់នៃការសិក្សាបន្តចំនួន ១២ ក្រេឌីត ក្នុងអំឡុងពេល ០៣ ឆ្នាំដើម្បីទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គណៈគិលានុបដ្ឋាកកម្ពុជាសូមណែនាំនិងជំរុញដល់គិលានុបដ្ឋាកគ្រប់ជំនាញបច្ចេកទេសត្រូវប្រតិបត្តិ គោលការណ៍ណែនាំនេះឲ្យបានទូលំទូលាយ និងហ្មត់ចត់ក្នុងការសិក្សាបន្តដើម្បីបង្កើនសមត្ថភាពឈានដល់ការ អនុវត្តន៍តាមនិយាមនៃការថែទាំ ក្រមសីលធម៌រក្សាបាននូវបច្ចុប្បន្នភាពចំណេះដឹង បច្ចេកវិទ្យាថ្មីៗដើម្បីធានា ការពារសុខភាព និងសុខមលភាពរបស់ប្រជាពលរដ្ឋកម្ពុជា។

គោលការណ៍ណែនាំស្តីពីការអភិវឌ្ឍនវិជ្ជាជីវៈបន្ត និងធ្វើការកែសម្រួលតាមការចាំបាច់។

រាជធានីភ្នំពេញថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៧

ជ. ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ

ប្រធាន

អ៊ុន សាន

# សេចក្តីថ្លែងអំណរគុណ

គោលការណ៍ណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់គិលានុបដ្ឋាកបានរៀបចំឡើងដោយ គណៈគិលានុបដ្ឋាកកម្ពុជា មានការជួយគាំទ្រផ្នែកបច្ចេកទេស និងថវិកាពីអង្គការ GIZ និងមានការជួយផ្តល់បច្ចេកទេសពីគណៈគិលានុបដ្ឋាកនិងឆ្មបប្រទេសថៃ។ គណៈគិលានុបដ្ឋាកសូមថ្លែងអំណរគុណចំពោះ លោក លោកស្រី និងអ្នកនាងកញ្ញាដែលមានរាយនាមខាងក្រោម៖

ក្រុមការងារបច្ចេកទេសចងក្រងគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់គិលានុបដ្ឋាក៖

| | |
|---|---|
| ១. លោក អ៊ុន សាន | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិលោក |
| ២. លោក កុយ វីរីយ៉ា | ប្រធានការិយាល័យគិលានុបដ្ឋាកនិងឆ្មប និងជាអតីតប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ |
| ៣. លោកស្រី ប្រាក់ម៉ានីឡា | សមាជិកក្រុមប្រឹក្សាភិបាលមន្ទីរពេទ្យកុមារអង្គរ |
| ៤. Ms. **Stephanie Ludwig** | Team Lead Cambodia "Support to the Initiative for ASEAN Integration (IAI)" GIZ |
| ៥. លោកស្រី កែ កំរង | Advisor-Mobility of Skilled Labour<br>GIZ support to "Initiative for ASEAN Integration (IAI)" |
| ៦. Ms. **Freudel Lucy** | GIZ |

# សេចក្តីផ្តើម

## គណៈគិលានុបដ្ឋាកកម្ពុជា

គណៈគិលានុបដ្ឋាកកម្ពុជា (CCN) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៧ ក្នុងគោលបំណងដើម្បីធានាសុវត្ថិភាពសាធារណៈ ដោយថែងក្នុងប្រព័ន្ធអប់រំគិលានុបដ្ឋាក និងការបង្កើតទិសដៅយុទ្ធសាស្ត្រសម្រាប់ CCN និងការត្រួតពិនិត្យមើលការងាររបស់បុគ្គលិកជាន់ខ្ពស់របស់ CCN។ ដោយមានកិច្ចសហប្រតិបត្តិការជាមួយនាយកដ្ឋានអប់រំគិលានុបដ្ឋាកនៃមន្ទីពេទ្យជាតិ និងសាលាបណ្តុះបណ្តាលគិលានុបដ្ឋាកតាមខេត្ត CCN មានសេចក្តីសោមនស្សរីករាយសូមបង្ហាញនូវគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍជំនាញវិជ្ជាជីវៈជាបន្ត (CPD) សម្រាប់គិលានុបដ្ឋាក។ គោលការណ៍ណែនាំថ្មីនេះត្រូវបានបង្កើតឡើងដើម្បីពិព័ណ៌នាពីការរំពឹងទុករបស់ CCN លើគិលានុបដ្ឋាកដែលបានចុះបញ្ជីទាំងអស់ទាក់ទងនឹងការថែរក្សាការអភិវឌ្ឍជំនាញវិជ្ជាជីវៈជាបន្តរបស់ពួកគេ។ គិលានុបដ្ឋាកដែលបានចុះបញ្ជីផ្តល់នូវការមើលថែរផ្ទាល់ដល់អ្នកជម្ងឺ និង/អតិថិជនភាគច្រើនបំផុតលើសេវាសុខភាពរយៈពេលពេញ ២៤ ម៉ោង។ គិលានុបដ្ឋាកមានចំនួនច្រើនជាងគេបង្អស់នៃអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលទាំងអស់ ហេតុដូច្នេះហើយបានជាមានសក្តានុពលដើម្បីរួមចំណែកលើសុខភាពប្រជាជន និងជួយថែរក្សាសុវត្ថិភាពអ្នកជម្ងឺ និងគុណភាពនៃសេវាថែទាំសុខភាព។ ការបង្កើតគោលការណ៍ណែនាំស្តីពី CPD សម្រាប់គិលានុបដ្ឋាកនៅក្នុងប្រទេសកម្ពុជា ត្រូវបានធ្វើឡើងដោយផ្អែកលើការត្រួតពិនិត្យលើក្របខណ្ឌ និងច្បាប់ជាតិ និងអន្តរជាតិជាច្រើនដូចខាងក្រោម៖

- គោលដៅអភិវឌ្ឍនិរន្តភាព (SDGs) របស់អង្គការសហប្រជាជាតិ
- ផែនការអភិវឌ្ឍកម្លាំងពលកម្មសុខភាព ២០១៦-២០២០ របស់ក្រសួងសុខាភិបាល
- គណៈកម្មាធិកាសម្របសម្រួលរួមរបស់អាស៊ានលើគិលានុបដ្ឋាក (AJCCN) ផែនការការងារ២០១៦ - ២០១៥
- ច្បាប់ស្តីពីការគ្រប់គ្រងការអនុវត្តផ្នែកសុខាភិបាល
- ផែនការយុទ្ធសាស្ត្រសុខាភិបាល ទី៣ ២០១៦-២០២០ (HSP3) របស់រាជរដ្ឋាភិបាលកម្ពុជា
- ផែនការយុទ្ធសាស្ត្រជាតិនៃក្រុមប្រឹក្សាវិជ្ជាជីវៈសុខាភិបាល ២០១៥ – ២០២០

## តួនាទីរបស់ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកកម្ពុជា

CCN ការពារសុខភាព និងសុខមាលភាពរបស់ប្រជាជនកម្ពុជាតាមរយៈ៖

- ការធានាថាគិលានុបដ្ឋាកទាំងអស់បានចុះបញ្ជី និងបង់ថ្លៃប្រចាំឆ្នាំដើម្បីរក្សានូវការចុះបញ្ជីនោះ
- ធានាលើការអនុវត្តស្តង់ដារវិជ្ជាជីវៈដូចជា ក្រមសីលធម៌សម្រាប់គិលានុបដ្ឋាក និយាមនៃការថែទាំអ្នកជម្ងឺ ក្របខណ្ឌនៃដំណើរការនៃការថែទាំ ពិធីការនៃការថែទាំ និងឯកសារគ្រឹះសម្រាប់គិលានុបដ្ឋាកដ៏ទៃទៀតដើម្បីលើកកម្ពស់គុណភាព និងសុវត្ថិភាពនៃការថែទាំសម្រាប់អ្នកជម្ងឺ និង/អតិថិជន
- ធានាថាគិលានុបដ្ឋាករក្សានូវសមត្ថភាព និងគាំទ្រនិយាមនៃការអនុវត្តវិជ្ជាជីវៈថែទាំអ្នកជម្ងឺ
- ការស៊ើបអង្កេតលើការតវ៉ារបស់គិលានុបដ្ឋាកទាក់ទងនឹងការអនុវត្តវិជ្ជាជីវៈ សមត្ថភាព និងសុខភាពផ្លូវចិត្ត ឬផ្លូវកាយ និងការកំណត់ការដាក់ទណ្ឌកម្មដែលសមស្រប (ការប្រព្រឹត្ត ឬសមត្ថភាពវិជ្ជាជីវៈ) ឬសកម្មភាពការពារ (ការប៉ះពាល់សុខភាពផ្លូវកាយ ឬផ្លូវចិត្ត)។

## ការអភិវឌ្ឍវិជ្ជាជីវៈបន្ត

ក្រុមប្រឹក្សាអន្តរជាតិនៃគិលានុបដ្ឋាក (ICN) កំណត់ការអភិវឌ្ឍវិជ្ជាជីវៈជាបន្ត (CPD) គឺជាដំណើរការយូរអង្វែងនៃការថែរទាំ និងការលើកកម្ពស់សមត្ថភាពរបស់គិលានុបដ្ឋាក។ CPD មានសារៈសំខាន់ណាស់សម្រាប់គិលានុបដ្ឋាកដើម្បីរក្សានូវសមត្ថភាពវិជ្ជាជីវៈតាមការរក្សាបច្ចុប្បន្នភាពជាមួយនឹងការផ្លាស់ប្តូរបរិស្ថាននៃការថែទាំសុខភាពយ៉ាងឆាប់រហ័សដោយសារតែការរីកចម្រើនជាបន្តបន្ទាប់លើចំណេះដឹង និងការអនុវត្តប្រកបដោយធាតុពិតជាក់ស្តែងបែបវិជ្ជាជីវៈ បច្ចេកវិទ្យាថ្មី និងកិច្ចអន្តរាគមន៍លើសេវាថែទាំសុខភាព។ គោលការណ៍ណែនាំស្តីពី CPD សម្រាប់គិលានុបដ្ឋាកនៅក្នុងប្រទេសកម្ពុជាត្រូវបានកំណត់ជា «ដំណើរការនៃការសិក្សាដ៏វែងឆ្ងាយក្នុងគោលបំណងបំពេញតាមតម្រូវការរបស់អ្នកជម្ងឺ និងការធ្វើឲ្យប្រសើរឡើងនូវលទ្ធផលផ្នែកសុខភាពតាមរយៈការកែលម្អរជាប្រព័ន្ធ និងការបង្កើនការយល់ដឹង ការស្វែងយល់ និង

ជំនាញ និងការអភិវឌ្ឍគុណសម្បត្តិបុគ្គលដែលចាំបាច់ដល់ការអនុវត្តកាតព្វកិច្ចវិជ្ជាជីវៈ ដោយរួមបញ្ចូលទាំងដំណើរការនៃការទទួលតួនាទី និងការទទួលខុសត្រូវថ្មី»។

## ការអភិវឌ្ឍវិជ្ជាជីវៈបន្តក្នុងបរិបទទីកន្លែងប្រកបវិជ្ជាជីវៈ

ការអនុវត្តមានន័យលើគ្រប់តួនាទីទាំងអស់ មិនថាបានប្រាក់ចំណូល ឬមិនបាន នៅគ្រប់ពេលវេលា និងទីកន្លែងដែលគិលានុបដ្ឋាកទាំងឡាយអាចប្រើប្រាស់ចំណេះដឹង និងជំនាញរបស់ពួកគេជាបុគ្គលអនុវត្តសេវាសុខភាពនៅក្នុងវិជ្ជាជីវៈរបស់ខ្លួន។ ការអនុវត្តក្នុងបរិបទនេះ មិនត្រូវបានដាក់កម្រិតទៅលើការផ្តល់ការថៃទាំព្យាបាលដោយផ្ទាល់នោះទេ។ ការអនុវត្តរួមបញ្ចូលទាំងការប្រើប្រាស់ចំណេះដឹងជំនាញវិជ្ជាជីវៈដែលមិនពាក់ព័ន្ធនឹងការព្យាបាលដោយផ្ទាល់ជាមួយអតិថិជននៅក្នុងមន្ទីរពេទ្យ គ្លីនិក មណ្ឌលសុខភាព មណ្ឌលកុមារកំព្រា ការងារទាក់ទងនឹងការគ្រប់គ្រង រដ្ឋបាល ការអប់រំ សិក្សាស្រាវជ្រាវ ផ្តល់ការប្រឹក្សាយោបល់ អ្នកដែលមានតួនាទីជាអ្នកបង្កើតបទប្បញ្ញត្តិ និងគោលការណ៍ផ្សេងៗ និងតួនាទីផ្សេងៗទៀតដែលមានផលប៉ះពាល់លើសុវត្ថិភាព ការផ្តល់សេវាប្រកបដោយប្រសិទ្ធិភាពក្នុងជំនាញវិជ្ជាជីវៈមើលថែរ។

## ភាពចាំបាច់នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត

ស្ថិតក្នុងបរិស្ថានមួយដែលមានការផ្លាស់ប្តូរឆាប់រហ័ស បច្ចេកវិទ្យាព័ត៌មាន ការកើនឡើងនូវការរំពឹងទុក និងតម្រូវការពីសាធារណជនលើគុណភាព និងការទទួលខុសត្រូវដ៏ធំធេង យើងចាំបាច់ត្រូវការ CPD សម្រាប់អ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដើម្បីរក្សានូវសមត្ថភាពជំនាញរបស់ពួកគេ។ គិលានុបដ្ឋាកជួបនូវបញ្ហាប្រឈមជាច្រើនក្នុងការទទួលយកនូវវិធីសាស្ត្រថ្មីៗលើការផ្តល់ការថៃទាំដែលនឹងផ្តល់នូវសេវាប្រកបដោយគុណភាពដែលយកចិត្តទុកដាក់លើអ្នកជម្ងឺ និង/អតិថិជនយ៉ាងពិតប្រាកដ។ ដើម្បីធានាបាននូវគុណភាពនៃការអនុវត្តសេវាថៃទាំនៅក្នុងប្រទេសកម្ពុជា CCN បានកត់សំគាល់ពីសារៈសំខាន់នៃសកម្មភាព CPD សម្រាប់គិលានុបដ្ឋាកទាំងអស់។ សកម្មភាព CPD ទាំងអស់នេះចាំបាច់ជួយសម្របសម្រួលដល់សមាសភាពនៃការចូលរួម ភាពពាក់ព័ន្ធទៅនឹងការអនុវត្តវិជ្ជាជីវៈពេលបច្ចុប្បន្ន និងការធ្វើសមាហរណកម្មលើចំណេះដឹងថ្មីទៅក្នុងការអនុវត្តជាក់ស្តែងដោយផ្អែកលើភស្តុតាងថ្មីៗ។

## អត្ថប្រយោជន៍ការអភិវឌ្ឍវិជ្ជាជីវៈបន្ត

CCN កត់សម្គាល់ឃើញថា CPD ដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយគិលានុបដ្ឋាកឲ្យទទួលយកនូវកម្រិតចំណេះដឹង ជំនាញ និងអកប្បកិរិយាទាន់សម័យ (ទាន់បច្ចុប្បន្នភាព) និងថ្មីដែលមិនត្រឹមតែបន្ថែមនូវអត្ថប្រយោជន៍ដែលអាចវាស់វែងបានលើការអនុវត្តវិជ្ជាជីវៈ ថែមទាំងជួយលើកកម្ពស់ និងពង្រឹងបន្ថែមនូវសុច្ចរិតភាពវិជ្ជាជីវៈដើម្បីជាប្រយោជន៍ដល់អ្នកជម្ងឺ ឬអតិថិជន។ ចំណេះដឹង ព័ត៌មាន និងជំនាញដែលទទួលបានរបស់គិលានុបដ្ឋាក ក្នុងនាមជាសិស្ស និង/ឬបុគ្គលិកហាត់ការ នឹងប្រើប្រាស់លែងបានតទៅទៀតក្នុងខណៈពេលណាមួយនោះ។ ការទទួលយកចំណេះដឹង និងជំនាញថ្មីៗសម្រាប់ជំនាញថែទាំគឺតែងតែមានជានិច្ច។ ដើម្បីការពារសាធារណជនដោយធានាការលើកកម្ពស់សុខភាពសង្គម គិលានុបដ្ឋាកត្រូវមានការប្តេជ្ញាផ្ទាល់ខ្លួនលើការបន្តអភិវឌ្ឍខ្លួនឥតឈប់ឈរ និងរក្សានូវការយល់ដឹងនូវចំណេះវិជ្ជាថ្មីៗដោយធ្វើឲ្យប្រសើរឡើងនូវចំណេះដឹង ជំនាញ និងអកប្បកិរិយាប្រកបដោយវិជ្ជាជីវៈ (HPCSA 2011)។

- CPD ជួយឲ្យអ្នកធ្វើបច្ចុប្បន្នភាពនូវអ្វីដែលអ្នកបានរៀននៅឯសាលា ឬមហាវិទ្យាល័យផ្នែកគិលានុបដ្ឋាក ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរលើការអនុវត្ត ការផ្លាស់ប្តូរដែលជាតម្រូវការរបស់អ្នកជម្ងឺ និងសេវាកម្ម និងការផ្លាស់ប្តូរលើការរំពឹងទុករបស់សង្គមលើរបៀបរបបធ្វើការរបស់គិលានុបដ្ឋាកទាំងអស់។
- CPD នឹងជួយអ្នកឲ្យប្រមើរមើល និងឆ្លើយតបទៅនឹងតម្រូវការនៃការផ្លាស់ប្តូរទាំងនេះ។ CPD អនុញ្ញាតឲ្យអ្នករក្សានូវការអនុវត្តដែលទាន់បច្ចុប្បន្នភាព និងសមស្រប និងជួយរក្សានូវស្តង់ដារវិជ្ជាជីវៈដែលជាតម្រូវការរបស់អ្នកពេញមួយជីវិតនៃអាជីពរបស់អ្នក។

CCN សង្ឃឹមថាគោលការណ៍ណែនាំនេះនឹងជាប្រយោជន៍សម្រាប់ការបង្កើនការអភិវឌ្ឍអាជីព និងការពេញចិត្តលើការងារក្នុងចំណោមគិលានុបដ្ឋាកក្នុងស្រុក និងក្នុងតំបន់។

## *គោលការណ៍សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត*

គោលបំណងចម្បងនៃ CPD គឺដើម្បីជួយលើកកម្ពស់សុវត្ថិភាព និងគុណភាពនៃការថែទាំដែលផ្តល់ឲ្យអ្នកជម្ងឺ និងសាធារណជន។

ក. <u>ការទទួលខុសត្រូវលើការរៀនសូត្រផ្ទាល់ខ្លួន</u>

បុគ្គលគ្រប់រូបគឺជាអ្នកទទួលខុសត្រូវលើការកំណត់ពីតម្រូវការ CPD ការរៀបចំធ្វើផែនការដើម្បីធ្វើឲ្យបានសម្រេចនូវតម្រូវទាំងនោះ និងការអនុវត្តតាម CPD ដែលនឹងគាំទ្រដល់ការអភិវឌ្ឍ និងការអនុវត្តជំនាញវិជ្ជាជីវៈរបស់ខ្លួន។

ខ. <u>ការឆ្លុះបញ្ចាំង</u>

ការអនុវត្តការថែទាំល្អតម្រូវឲ្យបុគ្គលឆ្លុះបញ្ចាំងជាប្រចាំលើនិយាមនៃការថែទាំអ្នកជម្ងឺ។

គ. <u>វិសាលភាពនៃការថែទាំ</u>

បុគ្គលគ្រប់រូបត្រូវតែមានសមត្ថភាព និងការអនុវត្តប្រកបដោយបច្ចុប្បន្នភាពគ្រប់ផ្នែកទាំងអស់។

ឃ. <u>ការរៀនសូត្រលក្ខណៈបុគ្គល និងក្រុម</u>

សកម្មភាព CPD របស់បុគ្គលម្នាក់គួរតែមានគោលបំណងដើម្បីថែរក្សា និងកែលម្អនិយាមនៃការថែទាំអ្នកជម្ងឺផ្ទាល់ខ្លួន ហើយក៏សម្រាប់ក្រុមផ្សេងៗទៀតនៅកន្លែងធ្វើការរបស់អ្នកដែរ។

ង. <u>ការកំណត់តម្រូវការ</u>

សកម្មភាព CPD របស់បុគ្គលម្នាក់គួរតែអនុវត្តឲ្យស្របតាមការវាយតម្លៃទាំងតម្រូវការវិជ្ជាជីវៈ និងតម្រូវការនៃសេវាកម្ម និងប្រជាពលរដ្ឋដែលប្រើប្រាស់វា។

ច. <u>លទ្ធផល</u>

បុគ្គលម្នាក់ៗត្រូវឆ្លុះបញ្ចាំងពីអ្វីដែលខ្លួនបានរៀនតាមរយៈ CPD របស់ខ្លួន និងកត់ត្រានូវរាល់ផលប៉ះពាល់ណាមួយ (ឬការរំពឹងទុកលើផលប៉ះពាល់នាពេលអនាគត)លើការប្រព្រឹត្ត និងការអនុវត្តរបស់បុគ្គលម្នាក់ៗ។

## គោលដៅការអភិវឌ្ឍវិជ្ជាជីវៈបន្ត

គោលដៅរបស់ CPD គឺជាប់ទាក់ទងនឹងការធ្វើឲ្យប្រសើឡើងនូវការអនុវត្តការងារ ការបង្កើនការរំពឹងទុកលើអាជីព ការបង្កើនសមត្ថភាពលើការរៀនសូត្រ ការលើកទឹកចិត្តឲ្យមានការចូលរួម និងការប្តេជ្ញាចិត្តលើការបន្តការរៀនសូត្រពេញមួយជីវិត និងការសម្របខ្លួន និងរៀបចំខ្លួនសម្រាប់ការផ្លាស់ប្តូរក្នុងការថែទាំសុខភាព។

## សកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត

CCN ទទួលស្គាល់នូវសកម្មភាព CPD ផ្សេងៗគ្នា ដែលមានចែងជាទូទៅក្នុងកម្រិតបីខាងក្រោម៖

**កម្រិតទី១៖** សកម្មភាពលើសេវាថែទាំ ឬការថែទាំសុខភាពដើម្បីទទួលបានចំណេះដឹង និងសមត្ថភាពជំនាញវិជ្ជាជីវៈ។

**កម្រិតទី២៖** សកម្មភាពក្នុងការអភិវឌ្ឍជំនាញវិជ្ជាជីវៈថែទាំ និងការអភិវឌ្ឍបុគ្គលិក

**កម្រិតទី៣៖** ការសិក្សាស្ថាប័ន

សកម្មភាពខាងក្រោមជាឧទាហរណ៍នៃសកម្មភាពដែល<u>**មិនមាន**</u>លក្ខណៈគ្រប់គ្រាន់សម្រាប់ CPD៖

- ការងារជាប្រចាំរាល់ថ្ងៃ
- កិច្ចការដែលបានសរសេរ (written assignment)
- ការចងក្រងសៀវភៅណែនាំលើការបណ្តុះបណ្តាលសិស្សសម្រាប់ប្រើប្រាស់ផ្ទៃក្នុង
- កិច្ចប្រជុំបុគ្គលិក និង/ឬប្រជុំរដ្ឋបាល
- ដំណើរទស្សនកិច្ច និង/ឬការទស្សនាការតាំងពិព័ណ និងការធ្វើបទបង្ហាញលើបច្ចេកវិទ្យា
- ភាពជាសមាជិកនៃអង្គភាពវិជ្ជាជីវៈ ក្រុមប្រឹក្សា ឬសមាគមជំនាញវិជ្ជាជីវៈ

- កិច្ចប្រជុំរៀបចំឡើងដោយក្រុមហ៊ុនឱសថ និងក្រុមហ៊ុនផលិត ឬអ្នកនាំចូលផលិតផល និងឧបករណ៍បច្ចេកទេស (រួមបញ្ចូលទាំងឧបករណ៍បច្ចេកវិទ្យាជំនួយ) ឬតំណាងចែកចាយផ្តាច់មុខក្នុងគោលបំណងនៃការធ្វើទីផ្សា និង/ឬការផ្សព្វផ្សាយផលិតផលរបស់ពួកគេ មិនមានលក្ខណៈស្របច្បាប់សម្រាប់ទទួលស្គាល់គុណភាព។

## លក្ខណៈវិនិច្ឆ័យ/តម្រូវការ និងការទទួលស្គាល់

CPD ជាតម្រូវការដើម្បីរក្សា និងពង្រឹងស្តង់ដារវិជ្ជាជីវៈរបស់គិលានុបដ្ឋាក និងដើម្បីផ្តល់នូវសុវត្ថិភាព និងគុណភាពនៃសេវាថែទាំ។ CPD ក៏ចូលរួមចំណែកដល់ការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់គិលានុបដ្ឋាកម្នាក់ៗផងដែរ។ ច្បាប់ថ្មីស្តីពីការគ្រប់គ្រងអ្នកអនុវត្តវិជ្ជាជីវៈសុខាភិបាល នឹងតម្រូវឲ្យគិលានុបដ្ឋាកគ្រប់រូបបំពេញគ្រប់សកម្មភាព CPD ដើម្បីមានសិទ្ធិស្របច្បាប់ក្នុងការទទួលបានអាជ្ញាប័ណ្ណដើម្បីអនុវត្តការថែទាំ។ ការខកខានក្នុងការបំពេញតាមតម្រូវការស្របតាមគោលការណ៍ណែនាំស្តីពី CPD របស់ CCN សម្រាប់គិលានុបដ្ឋាកនឹងពុំត្រូវបានផ្តល់អាជ្ញាប័ណ្ណជាគិលានុបដ្ឋាកសាជាថ្មីនោះឡើយ ហើយគិលានុបដ្ឋាកនឹងពុំមានសិទ្ធិអនុវត្តជំនាញវិជ្ជាជីវៈតទៅទៀតនោះទេ។

### ជំហ៊ានដែលគិលានុបដ្ឋាកត្រូវអនុវត្តតាម៖

ប្រសិនបើអ្នកពុំទាន់បានចុះបញ្ជីជាគិលានុបដ្ឋាកជាមួយ CCN សូមទៅធ្វើការចុះបញ្ជីជាគិលានុបដ្ឋាកឲ្យស្របតាមនីតិវិធីនៃការចុះបញ្ជីការរបស់ CCN (ឧបសម្ព័ន្ធទី១)។ បន្ទាប់មកសូមអនុវត្តតាមជំហ៊ានខាងក្រោម។

ប្រសិនបើអ្នកបានចុះបញ្ជីជាមួយ CCN រួចហើយនោះ សូមទាញយកនូវឯកសារមួយចំនួនខាងក្រោមពីគេហទំព័ររបស់ CCN http://cambodiancouncilofnurse.com/ និងបោះពុម្ព (print)វា ។

១. គោលការណ៍ណែនាំស្តីពី CPD សម្រាប់គិលានុបដ្ឋាក

២. កំណត់ត្រាសកម្មភាពរបស់បុគ្គល (ឧបសម្ព័ន្ធទី២)

មានការបានរំពឹងទុកថាគិលានុបដ្ឋាកម្នាក់ៗនឹងប្រមូលចំនួនពិន្ទុ (credits) ឲ្យបាន **១២ ក្នុងរយៈពេល៣ឆ្នាំ ឬ០៣ credits** ក្នុង១ឆ្នាំ។ ចំនួន credits ទាំងនេះអាចប្រមូលបានតាមការចូលរួមក្នុងសកម្មភាពផ្សេងៗ សូមមើលតារាងទិដ្ឋភាពទូទៅនៃប្រព័ន្ធ credit។

សូមបំពេញនូវសកម្មភាពក្នុងកំណត់ត្រាសកម្មភាពបុគ្គលម្នាក់ៗ (ឧបសម្ព័ន្ធទី២) និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធផ្សេងៗដូចជា វិញ្ញាបនបត្រនៃការចូលរួម និងលិខិតសរសើរ ឬឯកសារចម្លងពីអត្ថបទកាសែតដែលបានចេញផ្សាយ សេចក្តីថ្លែងការណ៍នៃការងារជាសាស្ត្រាចារ្យ ឬអ្នកបង្វឹកការងារ ឬពានរង្វាន់ជាផ្លូវការមួយដែលបញ្ជាក់ថាបានបញ្ចប់ការសិក្សា ឬការងាររហូតដល់ថ្ងៃនេះសម្រាប់សកម្មភាព CPD។

| |
|---|
| **ចំណាំ៖ សកម្មភាព CPD ត្រូវតែបានទទួលស្គាល់ដោយ CCN តាមរយៈអ្នករៀបចំកម្មវិធី (<u>មិនមែនតាមរយៈគិលានុបដ្ឋាកនោះទេ</u>)។ គ្រប់អ្នករៀបចំកម្មវិធី ត្រូវទាក់ទងមក CCN ដើម្បីឲ្យមានការយល់ស្របទទួលស្គាល់លើសកម្មភាពមុនពេលអនុវត្តសកម្មភាពនោះ ដូច្នេះពិន្ទុ credit CPD នឹងត្រូវបានទទួលស្គាល់រួចជាស្រេច។** |
| **សូមទំនាក់ទំនងមកកាន់ CCN តាមរយៈ៖ [info@cambodiancouncilofnurse.com](mailto:info@cambodiancouncilofnurse.com)** |

សូមកត់ចំណាំថា CCN នឹងទទួលស្គាល់អ្នកផ្តល់សកម្មភាព CPD ដ៏ជាក់លាក់មួយចំនួនរួមមាន ក្រសួងសុខាភិបាល (MoH) សាកលវិទ្យាល័យ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលតាមតំបន់ (RTCs) សមាគមជំនាញវិជ្ជាជីវៈអន្តរជាតិ តំបន់ និងកម្ពុជាសម្រាប់គិលានុបដ្ឋាក និងម្ចាស់ជំនួយផ្នែកសុខាភិបាល។

នៅពេលផ្តល់អាជ្ញាប័ណ្ណឡើងវិញនៅតាមការិយាល័យចុះឈ្មោះតាមបណ្តាខេត្ត-ក្រុង សូមភ្ជាប់មកជាមួយនូវកំណត់ត្រាសកម្មភាពបុគ្គល និងវិញ្ញាបនបត្រនៃការចូលរួម។

នៅពេលដែលគ្រប់ឯកសារដែលទាក់ទងនឹង CPD ត្រូវបានផ្ទៀងផ្ទាត់ដោយការិយាល័យចុះឈ្មោះខេត្ត-ក្រុង និងឯកសារនៃការចុះឈ្មោះគ្រប់គ្រាន់ហើយ អ្នកមានសិទ្ធិគ្រប់គ្រាន់ស្របច្បាប់ក្នុងការទទួលបានការផ្តល់អាជ្ញាប័ណ្ណគិលានុបដ្ឋាកជាថ្មី។

# ជំហាននៃ CPD


តើអ្នកជាគិលានុបដ្ឋាកដែលបាន ចុះបញ្ជីរួចហើយឬនៅ?
នៅទេ
ធ្វើដំណើរទៅកាន់ការិយាល័យចុះ ឈ្មោះខេត្ត-ក្រុង
ចុះឈ្មោះជាគិលានុបដ្ឋាកតាម នីតិវិធីនៃការចុះឈ្មោះរបស់ CCN
រួចហើយ
ស្វែងរក និងទាញយកឯកសារ CPD ពីគេហទំព័ររបស់ CCN http://cambodiancouncilofnurse.com/
ប្រមូលចំនួន creditsយ៉ាងតិច៤ ក្នុង១ឆ្នាំ/១២ credits ក្នុងរយៈពេល៣ឆ្នាំដោយចូលរួមក្នុងសកម្មភាពដែលទទួលស្គាល់ដោយ CPD
ចំណាំ
សកម្មភាព CPD ត្រូវតែបានទទួលស្គាល់ដោយ CCN តាមរយៈអ្នករៀបចំកម្មវិធី (មិនមែនតាមរយៈគិលានុបដ្ឋាកនោះទេ) ដូច្នេះ ពិន្ទុ credit CPD នឹងត្រូវបានទទួលស្គាល់រួចជាស្រេច
គ្រប់អ្នករៀបចំកម្មវិធី ត្រូវទាក់ទងមក CCN ដើម្បីឲ្យមានការយល់ស្របទទួលស្គាល់លើសកម្មភាពមុនពេលអនុវត្ត សកម្មភាពនោះ
កុំភ្លេច៖
១. បំពេញកំណត់ត្រាសកម្មភាពបុគ្គល
២. ប្រមូលវិញ្ញាបនបត្រនៃការចូលរួម
នៅពេលដល់ពេលកំណត់ដែលត្រូវសុំអាជ្ញាប័ណ្ណថៃទាំថ្មី បន្ទាប់ពីរយៈពេល៣ឆ្នាំ សូមយកឯកសារ CPD របស់អ្នកទៅកាន់ការិយាល័យចុះឈ្មោះខេត្ត-ក្រុងដោយភ្ជាប់ជាមួយនូវឯកសារចាំបាច់មួយចំនួនសម្រាប់ការសុំអាជ្ញាប័ណ្ណជាថ្មី
ការិយាល័យចុះឈ្មោះតាមតំបន់នីមួយៗនឹងធ្វើការផ្ទៀងផ្ទាត់សកម្មភាព CPD របស់អ្នក និងផ្តល់ជូនអាជ្ញាប័ណ្ណជាថ្មីលើការថៃទាំដល់អ្នក

## និជ្ជភាពពន្ធនៅនៃប្រព័ន្ធ Credit

| កម្រិត | សកម្មភាព | CREDITS | ការពន្យល់ |
|---|---|---|---|
| ១ | ការចូលរួមវគ្គសិក្សាដូចជា ការបណ្តុះបណ្តាល សិក្ខាសាលា មហាសន្និបាត។ល។ | ១ | ការចូលរួមរយៈពេល៨ម៉ោង |
| ១ | មហាសន្និបាត/សមាជស្តីពីការថែទាំសុខភាព (ឧ. ទិវាគិលានុបដ្ឋាកអន្តរជាតិ) | ១ | ការចូលរួមរយៈពេល៨ម៉ោង |
| ១ | ការចំណាយពេលវេលាលើការរៀបចំផែនការ ចាត់ចែង ឬការជួយសម្របសម្រួលដល់សកម្មភាពផ្សេងៗដែលទាក់ទងការថែទាំ | ១ | រយៈពេល៨ម៉ោង |
| ២ | ការបោះពុម្ព (ឧ. ទស្សនាវដ្តី ឯកសារសន្និសិទ មិនមែនខិតប័ណ្ណផ្សព្វផ្សាយ និងផ្ទាំងរូបភាពផ្សព្វផ្សាយ (poster) នោះទេ | ៥/៣ | ទី១ /ទី២ និងអ្នកនិពន្ធបន្តបន្ទាប់ទៀត |
| ២ | ការសរសេរសៀវភៅសិក្សា | ៥/៣ | • ទី១ /ទី២ និងអ្នកនិពន្ធបន្តបន្ទាប់ទៀត<br>• យ៉ាងតិចបំផុត ៥០ ទំព័រនៃទំហំក្រដាស A៤ សរុបទាំងសេចក្តីយោង |
| ២ | អ្នកត្រួតពិនិត្យលើឯកសារស្រាវជ្រាវ | ២ | អ្នកពិនិត្យឯកសារស្រាវជ្រាវ១ |
| ២ | អ្នកត្រួតពិនិត្យលើសំណើរ និងសីលធម៌នៃការស្រាវជ្រាវ | ២ | ការស្រាវជ្រាវ១ |
| ២ | អ្នកអានអ្នកត្រួតពិនិត្យជាដៃគូរ (peer reviewer reader) | ២ | ការត្រួតពិនិត្យ១ |
| ២ | អ្នកត្រួតពិនិត្យខាងក្រៅលើនិក្ខេបបទ | ៣ | និក្ខេបបទ១ |
| ២ | សាស្ត្រាចារ្យ (lecturer) និងការចូលរួមជាអ្នកឆ្លងឆ្លើយសំនួរ | ១ | ការបង្រៀន (lecture) រយៈពេល៣ម៉ោង |

| | | | |
|---|---|---|---|
| ២ | គ្រូបង្ហាត់ (Preceptor) និងអ្នកណែនាំដល់និស្សិតគិលានុបដ្ឋាក/គិលានុបដ្ឋាក និងគោលការណ៍ណែនាំការអនុវត្តការថែទាំព្យាបាល | ២/៤ | ១ត្រីមាស/១ឆមាស |
| ៣ | ការអប់រំបន្តដែលនាំទៅដល់កម្រិតមួយខ្ពស់ | ៩ | ១ឆ្នាំ |
| ៣ | ជំនាញការថែទាំ/ការបណ្តុះបណ្តាលរយៈពេលខ្លី (ពី៣សប្តាហ៍ឡើងទៅ) មិនបាននាំទៅដល់កម្រិតមួយខ្ពស់នោះទេ | ៥ | |

## ទំនាក់ទំនងសំខាន់ៗ៖

***Cambodia Council of Nursing:***

បន្ទប់ ២០៣ ជាន់ទី១ អគារទី២របស់នាយករដ្ឋមន្ត្រី

៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ កម្ពុជា

ទូរស័ព្ទ៖ ០៧៧
៦១៦១៩៦/០១១៩២៩២២២/០១២៩២៥៨៦៣/០៧០៨៨៨២២០/០៩២៣២៦៦៩
៩

អ៊ីម៉េល៖ info@cambodiancouncilofnurse.com

គេហទំព័រ៖ http://cambodiancouncilofnurse.com/

ហ្វេសប៊ុក៖ https://www.facebook.com/CambodianCouncilofNurses/

# ឧបសម្ព័ន្ធទី១៖ ដំណើរការចុះបញ្ជីគិលានុបដ្ឋាក

ដំណើរការនៃការចុះបញ្ជី៖ មូលដ្ឋានជាក្រដាស



ទាញយកទម្រង់ការចុះបញ្ជី បំពេញ និងភ្ជាប់មកជាមួយនូវសញ្ញាបនប័ត្រដែលបញ្ជាក់ពីសាលាក្រុង-ខេត្ត ព្រឹត្តិបត្រពិន្ទុ លិខិតថ្កោលទោស និងរូបថត ៤*៦/រូបថតឌីជីថល (មួយកំណាត់ខ្លួន)និង ថវិកាដែលត្រូវបង់បង់ (អាចជាថវិកាថ្លៃប្រៃសណីយ៍ ប្រសិនបើត្រូវការផ្ញើវិញ្ញាបនប័ត្រត្រលប់វិញតាមប្រៃសណីយ៍)

៣ សប្តាហ៍ក្រោយមកអ្នកនឹងទទួលបានវិញ្ញាបនប័ត្រសមាជិកពី ក.គិ.ខ ឬគ.គិ.កតាមរយៈប្រៃសណីយ៍ ទៅកាន់អាសយដ្ឋាននៃកន្លែងធ្វើការ ឬគេហដ្ឋានរបស់អ្នក

ក.គិ.ខ

គ.គិ.ក

ដំណើរការនៃការចុះ៖ តាមរយៈអនឡាញ

(online registration)



ត្រៀមរួចជាស្រេចនូវសញ្ញាបនប័ត្រដែលបញ្ជាក់ពីសាលាក្រុង-ខេត្ត ព្រឹត្តិបត្រពិន្ទុ លិខិតថ្កោលទោស និងរូបថត ៤*៦/រូបថតឌីជីថល (មួយកំណាត់ខ្លួន)និង ថវិកាដែលត្រូវបង់ រួចចូលទៅកាន់គេហទំព័ររបស់ គ.គិ.ក ចាប់ផ្តើមបំពេញទម្រង់ការចុះបញ្ជីតាមអនឡាញ និងបង់ថវិកាទៅឲ្យ គ.គិ.ក ដោយផ្ទាល់

៣ សប្តាហ៍ក្រោយមកអ្នកនឹងទទួលបានវិញ្ញាបនប័ត្រសមាជិកពី ក.គិ.ខ ឬគ.គិ.កតាមរយៈ អ៊ីម៉ែល (ជាជម្រើស អាចបោះពុម្ពចេញបាន)

ក.គិ.ខ

គ.គិ.ក

ដំណើរការនៃការចុះ៖ តាមរយៈអនឡាញ

(offline registration)



ត្រៀមរួចជាស្រេចនូវសញ្ញាបនប័ត្រដែលបញ្ជាក់ពីសាលាក្រុង-ខេត្ត ព្រឹត្តិបត្រពិន្ទុ លិខិតថ្កោលទោស និងរូបថត ៤*៦/រូបថតឌីជីថល (មួយកំណាត់ខ្លួន)និង ថវិកាដែលត្រូវបង់ រួចចូលទៅកាន់គេហទំព័ររបស់ គ.គិ.ក ចាប់ផ្តើមបំពេញទម្រង់ការចុះបញ្ជីតាមអូហ្វឡាញ និងបង់ថវិកាទៅឲ្យ គ.គិ.ក ដោយផ្ទាល់

៣ សប្តាហ៍ក្រោយមកអ្នកនឹងទទួលបានវិញ្ញាបនប័ត្រសមាជិកពី ក.គិ.ខ ឬគ.គិ.កតាមរយៈ អ៊ីម៉ែល (ជាជម្រើស អាចបោះពុម្ពចេញបាន)

ក.គិ.ខ

គ.គិ.ក

# ឧបសម្ព័ន្ធទី២៖ កំណត់ត្រាសកម្មភាពបុគ្គល

| | |
|---|---|
| | **គណៈគិលានុបដ្ឋាកកម្ពុជា**<br>**កំណត់ត្រាសកម្មភាពបុគ្គល** |

សូមបំពេញ និងជូនត្រឡប់វិញដល់៖ ការិយាល័យចុះឈ្មោះគិលានុបដ្ឋាកខេត្ត-ក្រុង

សូមភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រ

| | |
|---|---|
| គោត្តនាម | |
| នាមខ្លួន | |
| លេខ អត្តសញ្ញាណប័ណ្ណ | |
| ថ្ងៃដែលបាន ប្រគល់ | |

សូមជ្រើសរើសនូវប្រភេទកន្លែងដែលអ្នកកំពុងធ្វើការពេលបច្ចុប្បន្ន៖

☐ សេវាសាធារណៈ ☐ វិទ្យាស្ថានបណ្តុះបណ្តាល ☐ ការអនុវត្តឯកជន ☐ ផ្សេងៗ ...............................

**ចំណុចដែលកើតឡើង** (សូមភ្ជាប់នូវវិញ្ញាបនបត្រ)

| ឈ្មោះអ្នកដែលផ្តល់ឲ្យ | ការពិពិណនាពីសកម្មភាព/លេខនៃការទទួលស្គាល់ | កាលបរិច្ឆេទ | | កម្រិតទី១ | កម្រិតទី២ | កម្រិតទី៣ | សរុប |
|---|---|---|---|---|---|---|---|
| | | ពីថ្ងៃទី | ដល់ថ្ងៃទី | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

| ឈ្មោះអ្នកដែលផ្តល់ឲ្យ | ការពិពិណនាពីសកម្មភាព/លេខនៃការទទួលស្គាល់ | កាលបរិច្ឆេទ | | កម្រិតទី១ | កម្រិតទី២ | កម្រិតទី៣ | សរុប |
|---|---|---|---|---|---|---|---|
| | | ពីថ្ងៃទី | ដល់ថ្ងៃទី | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| សរុប | | | | | | | |

ខ្ញុំ ជាអ្នកចុះហត្ថលេខានេះ សូមបញ្ជាក់ថាគ្រប់ព័ត៌មានដែលមានចែងក្នុងកំណត់ត្រាសកម្មភាពបុគ្គល និងវិញ្ញាបនបត្រដែលជូនភ្ជាប់នេះពិតជាត្រឹមត្រូវពិតប្រាកដមែន។

______________________ ______________________

**ហត្ថលេខា** **កាលបរិច្ឆេទ**

# ឧបសម្ព័ន្ធទី៣៖ អន្តរភាពក្នុងស្រុកដែលជាតំណាងឲ្យ CNN

| | |
|---|---|
| **រាជធានី កណ្តាល (មៅ តាន់ណារី)៖** | |
| ភ្នំពេញ | ០១២ ៨៩២ ៧២៨ (យឹម សំអាង) |
| កណ្តាល | ០១២ ៨៥០ ០៩៣ (ឈួក សារ៉ាន់) |
| កំពង់ស្ពឺ | ០១៦ ៩០៤ ៥០៩ (ចក់ ថៃ) |
| កំពង់ឆ្នាំង | ០១៦ ៣០១ ១៩៧ (ម៉ម ម៉ាល័យ)<br>០១២៥៥១ ៨០៧ និង ០៩៧ ៧៧៧ ១៧៦៩ (វង្ស វិចិត្រ) |
| **ភូមិភាគបាត់ដំបង៖ ០១២ ៩៧៧ ៣២៣ (យក់ សុត្ថា)** | |
| បាត់ដំបង | ០៧៧ ៥៨៥ ២៥១ និង ០១២ ៩៧៤ ៨៦៦ (លោកស្រី ហុក ដួងច័យ) |
| ឧត្តរមានជ័យ | ០១២ ៥៩០ ០៨៥ និង ០១២ ៥៨៦ ៩៤៧ និង ០៩៨ ៥៨៦ ៩៤៧ (សី សាព៉ំ) |
| បន្ទាយមានជ័យ | ០១២៩៣៩៦៣៥ (កែវ សំណាង)<br>០១២ ៦២០ ១៥៤ (ហាម ភីរុណ) |
| សៀមរាប | ០១២ ៨០៦ ២១១ (និន នារីរតន៍) |
| ពោធិ៍សាត់ | ០៩២២៩៩០២៩, ០៩២ ៨១០ ១៩៤ (អេង ធាព៉) |
| ប៉ៃលិន | ០១៦ ៣៧៥ ២៣១ (សុខ សុន) |
| **ភូមិភាគកំពង់ចាម៖ ០១២ ៨៧០ ៨២៧ (មៀច លឹមហួរ)** | |
| កំពង់ចាម | ០១៧ ៥០៣ ៣៣៣ (យិន វិបុល) |
| ព្រៃវែង | ០១២ ៥៦៥ ៥៤១ (ពេជ្រ ពិសាល) |
| ស្វាយរៀង | ០១១ ៣៥០ ៦០៧ ,០៩៧ ៤៧៩ ៩៨៨៨ (សូ វណ្ណារីនី) |
| កំពង់ធំ | ០៩២ ៦២០ ០២៧ (កុយ វិជ្ជារុធ) |
| ត្បូងឃ្មុំ | ០១២ ៨៩២ ១០១,០៩២ ៨៥៨ ៥៥៤ (ហ៊ី សុវណ្ណ |
| **ភូមិភាគស្ទឹងត្រែង៖ ០៧៧ ៩៩៩ ៤៦៨/ ០៩៧ ៩៩៩ ៩៤៦៨ (ហៀ សេធិល)** | |
| ស្ទឹងត្រែង | ០១២ ៥៨៦ ៩៤៧ (សែន ស៊ុធ្ធ) |

| | |
|---|---|
| ព្រះវិហារ | ០១២ ៣៧៥ ០៩៦ (បេត ផល្លា) |
| ក្រចេះ | ០១២ ៤៧៩ ២៧១ (ខូវ បានលី) |
| មណ្ឌលគីរី | ០៩៧ ៥២៧ ៧៧៨១ (ដួង សារ៉ា) |
| រតនៈគីរី | ០១២ ៦២៩ ៦៩១ (ច័ន្ទ ម៉ារ៉ាឌី) |
| **ភូមិភាគកំពតៈ ០១២ ៩១៧ ៦៨៣ (សែន ពិសិដ្ឋ)** | |
| កំពត | ០៩២ ៨២៣ ៦៧៧/០៩៧ ៩០២ ៥៨៥៨ (មុនី) |
| កែប | ០១២ ៦២៦ ៩៩៥ (នី បូទិត្យ) |
| ព្រះសីហនុ | ០១២ ៩៨៨ ៣៨២ (កៅ ហាក់) |
| កោះកុង | ០១១ ៨២៨ ៦២៩ (សុខ មុនី) |
| តាកែវ | ០៩២ ៥០៤ ០៩០ (ជា ហួត)/ ០១១ ៥២៨ ២៩៧ (ឆឹង សុភន) |